**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ**១៧៦១៧ **អយក.ជាវ**

ថ្ងៃ ចន្ទ ១៥រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០២០

**ជម្រាបជូន**
**ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គាធិការ**
**ឯកឧត្តម លោកជំទាវ សាកលវិទ្យាធិការ នាយកវិទ្យាស្ថាន**
**ឯកឧត្តម លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទនីស្តីការក្រសួង**
**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ ៖** ករណីការធ្វើវិចារណកម្មនិងការពង្រឹងប្រសិទ្ធភាពចំណាយសម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ របស់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។

**យោង ៖** សារាចរណែនាំលេខ០០១ សហវ.អថ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជ្រាបថា៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញសារាចរណែនាំលេខ០០១ សហវ.អថ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការធ្វើវិចារណកម្មនិងការពង្រឹងប្រសិទ្ធភាពចំណាយសម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងចំណាយនិងកាត់សន្សំឥណទានថវិកាលើមុខសញ្ញាចំណាយមួយចំនួនទៅបម្រើឱ្យសកម្មភាពចាំបាច់និងបន្ទាន់ថ្មីគឺការការពារប្រយុទ្ធប្រឆាំងនិងទប់ស្កាត់ហានិភ័យរីករាលដាលនៃជំងឺកូវីដ១៩(Covid-19) ដើម្បីធានាសុវត្ថិភាពសុខុមាលភាពជូនប្រជាពលរដ្ឋទូទាំងប្រទេស។ ក្នុងន័យនេះ ដើម្បីចូលរួមអនុវត្តក្នុងស្មារតីបុរេសកម្មដោយអនុលោមទៅតាមសារាចរណែនាំលេខ០០១ សហវ.អថ ឱ្យប្រព្រឹត្តទៅប្រកបដោយភាពច្បាស់លាស់ ត្រឹមត្រូវ និងទាន់ពេលវេលា ក្រសួងស្នើសុំកំណត់ ដូចខាងក្រោម៖

១-គ្រប់អង្គភាព ត្រូវកាត់សន្សំនិងព្យួរលើមុខសញ្ញាចំណាយមួយចំនួន រួមមាន៖

១.១-រដ្ឋបាលកណ្តាល៖

-ប្រេងឥន្ធនៈនិងប្រេងរំអិល៖ ត្រូវកាត់សន្សំចំនួន**១៣%** នៃឥណទានដើមឆ្នាំ ដែលស្ថិតក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា គឺជំពូក៦០(ការទិញ) គណនី៦០០១(សម្ភារផ្គត់ផ្គង់ថែទាំ) អនុគណនី៦០០១៥(ប្រេងឥន្ធនៈនិងប្រេងរំអិល)



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

-សម្ភារការិយាល័យ៖ ត្រូវកាត់សន្សំចំនួន១៥% នៃឥណទានដើមឆ្នាំ ដែលស្ថិតក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាគឺជំពូក៦០(ការទិញ) គណនី៦០០២(សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល) អនុគណនី៦០០២១(សម្ភារការិយាល័យ)

-សម្ភារនិងបរិក្ខារបច្ចេកវិទ្យាព័ត៌មានវិទ្យា៖ ត្រូវកាត់សន្សំចំនួន១៥% នៃឥណទានដើមឆ្នាំ ដែលស្ថិតក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា គឺជំពូក៦០(ការទិញ) គណនី៦០០៥(សម្ភារតូចតាច សង្ហារិម និងបរិក្ខារបច្ចេកទេស) អនុគណនី៦០០៥៥(សម្ភារនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា)

-សម្ភារនិងឧបករណ៍ដឹកជញ្ជូន៖ ត្រូវព្យួរការទិញរថយន្តចំនួន១០០% នៃឥណទានដើមឆ្នាំ ដែលស្ថិតក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា គឺជំពូក៦០(ការទិញ) គណនី៦០០៥(សម្ភារតូចតាច សង្ហារិម និងបរិក្ខារបច្ចេកទេស) អនុគណនី៦០០៥៤(សម្ភារនិងឧបករណ៍ដឹកជញ្ជូន)

-បេសកកម្មក្រៅប្រទេស៖ ត្រូវកាត់សន្សំចំនួន៥០% នៃឥណទានដើមឆ្នាំ ដែលស្ថិតក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាគឺជំពូក៦១(សេវាកម្ម) គណនី៦១១៣(សោហ៊ុយបេសកកម្មក្រៅប្រទេស) អនុគណនី៦១១៣១(សោហ៊ុយដឹកជញ្ជូន) ៦១១៣២(សោហ៊ុយបេសកកម្ម) និង៦១១៣៣(សោហ៊ុយស្នាក់នៅ)។

១២-មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត៖ ត្រូវព្យួរការទិញរថយន្តចំនួន១០០% នៃឥណទានដើមឆ្នាំសម្រាប់សម្ភារនិងឧបករណ៍ដឹកជញ្ជូន ដែលស្ថិតក្នុងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា គឺជំពូក៦០(ការទិញ) គណនី៦០០៥(សម្ភារតូចតាច សង្ហារិម និងបរិក្ខារបច្ចេកទេស) អនុគណនី៦០០៥៤(សម្ភារនិងឧបករណ៍ដឹកជញ្ជូន)។

២-គ្រប់អង្គភាព ត្រូវគោរពតាមវិធានការនិងធ្វើវិចារណកម្មចំណាយលើមុខសញ្ញាចំណាយខាងលើ (ត្រង់ចំណុចទី១) ឱ្យបានត្រឹមត្រូវ ច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ហើយប្រកបដោយភាពជាម្ចាស់និងទទួលខុសត្រូវខ្ពស់ ។

៣-គ្រប់អង្គភាព ត្រូវពង្រឹងការគ្រប់គ្រងចំណាយនិងធ្វើវិចារណកម្មចំណាយពីមុខសញ្ញាចំណាយមួយចំនួនដែលមិនចាំបាច់ឬមិនទាន់ចាំបាច់ខ្លាំង ហើយមិនសូវប៉ះពាល់សកម្មភាពការងារអាទិភាព។

៤-គ្រប់អង្គភាព ត្រូវពិនិត្យនិងផ្ទៀងផ្ទាត់ទំហំឥណទានថវិកា ដែលបានកាត់សន្សំនិងព្យួរខាងក្រោមឱ្យបានប្រាកដប្រជា ដោយក្រសួងបានតម្រឹមឈរលើមូលដ្ឋាននៃសារាចរណែនាំលេខ០០១ សហវ.អថ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ រួមមាន៖

ឯកតា៖ លានរៀល

| បរិយាយ | ច្បាប់ថវិកា ឆ្នាំ២០២០ | ឥណទាន កាត់សន្សំ | ឥណទាន ក្រោយកាត់សន្សំ | ផ្សេងៗ |
|---|---|---|---|---|
| **សរុបរួមក្រសួង** | **3,207,220.0** | **7,799.9** | **3,199,420.1** | |
| **រដ្ឋបាលកណ្តាល** | **374,072.4** | **6,959.9** | **367,112.5** | |
| កម្មវិធីទី១ | **74,168.2** | **730.9** | **73,437.3** | |
| នា.អប់រំកុមារតូច | 12,336.1 | 188.5 | 12,147.6 | |
| នា.បឋមសិក្សា | 3,568.4 | 57.5 | 3,510.9 | |

| បរិយាយ | ច្បាប់ថវិកា ឆ្នាំ២០២០ | ឥណទានកាត់សន្សំ | ឥណទានក្រោយកាត់សន្សំ | ផ្សេងៗ |
|---|---|---|---|---|
| នា.មធ្យមសិក្សាចំណេះទូទៅ | 7,830.9 | 110.8 | 7,720.1 | |
| នា.អប់រំក្រៅប្រព័ន្ធ | 2,293.0 | 28.0 | 2,265.0 | |
| នា.សុខភាពសិក្សា | 778.7 | 13.9 | 764.8 | |
| នា.តម្រង់ទិសវិជ្ជាជីវៈ | 3,902.6 | 68.1 | 3,834.5 | |
| នា.បណ្តុះបណ្តាល និងវិក្រឹតការ | 11,767.1 | 109.0 | 11,658.1 | |
| នា.អភិវឌ្ឍកម្មវិធីសិក្សា | 28,956.5 | 112.6 | 28,843.9 | |
| នា.អប់រំពិសេស | 2,734.9 | 42.4 | 2,692.5 | |
| **កម្មវិធីទី២** | **40,200.9** | **1,324.3** | **38,876.6** | |
| នា.ឧត្តមសិក្សា | 3,312.6 | 143.7 | 3,168.9 | |
| នា.ស្រាវជ្រាវវិទ្យាសាស្ត្រ | 1,035.6 | 36.9 | 998.7 | |
| សា.វិទ្យាល័យភូមិន្ទភ្នំពេញ | 3,956.2 | 94.6 | 3,861.6 | |
| សា.វិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ | 1,612.1 | 61.3 | 1,550.8 | |
| សា.វិទ្យាល័យ ជា ស៊ីម កំចាយមារ | 3,125.5 | 83.8 | 3,041.7 | |
| វិ.ស្ថានបច្ចេកវិទ្យាកម្ពុជា | 5,791.7 | 257.5 | 5,534.2 | |
| វិ.ស្ថានជាតិអប់រំ | 7,272.8 | 87.6 | 7,185.2 | |
| សា.វិទ្យាល័យស្វាយរៀង | 3,872.5 | 115.0 | 3,757.5 | |
| សា.វិទ្យាល័យមានជ័យ | 1,864.7 | 73.8 | 1,791.0 | |
| សា.វិទ្យាល័យបាត់ដំបង | 2,205.0 | 94.4 | 2,110.6 | |
| គ.ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | 1,005.0 | 70.6 | 934.5 | |
| វិ.ស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | 2,264.9 | 57.1 | 2,207.9 | |
| សា.វិទ្យាល័យក្រចេះ | 1,267.4 | 59.1 | 1,208.3 | |
| វិ.ស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ | 1,614.9 | 89.1 | 1,525.8 | |
| **កម្មវិធីទី៣** | **49,953.3** | **697.8** | **49,255.5** | |
| នា.អប់រំកាយ និងកីឡា | 13,193.7 | 148.7 | 13,045.0 | |
| នា.អប់រំកាយ និងកីឡាសិស្ស-និស្សិត | 7,677.3 | 298.9 | 7,378.4 | |
| វិ.ស្ថានជាតិអប់រំកាយ និងកីឡា | 2,016.4 | 64.4 | 1,952.0 | |
| មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | 27,065.9 | 185.8 | 26,880.1 | |
| **កម្មវិធីទី ៤** | **11,976.5** | **258.9** | **11,717.6** | |
| នា.យុវជន | 7,026.0 | 55.0 | 6,971.0 | |
| នា.គ្រប់គ្រងមជ្ឈមណ្ឌលយុវជន | 3,395.4 | 96.4 | 3,299.0 | |
| នា.សហប្រតិបត្តិការកាយរឹទ្ធិ | 1,555.1 | 107.5 | 1,447.6 | |
| **កម្មវិធីទី ៥** | **197,773.5** | **3,947.9** | **193,825.6** | |

| បរិយាយ | ច្បាប់ថវិកា ឆ្នាំ២០២០ | ឥណទាន កាត់សន្សំ | ឥណទាន ក្រោយកាត់សន្សំ | ផ្សេងៗ |
|---|---|---|---|---|
| នា.ផែនការ | 2,019.4 | 67.7 | 1,951.7 | |
| នា.បុគ្គលិក | 83,709.3 | 60.7 | 83,648.6 | |
| នា.ហិរញ្ញវត្ថុ | 80,648.0 | 2,790.9 | 77,857.1 | |
| នា.សវនកម្មផ្ទៃក្នុង | 989.1 | 12.7 | 976.4 | |
| នា.ធានាគុណភាពអប់រំ | 3,550.5 | 178.0 | 3,372.5 | |
| អធិ.រដ្ឋបាលនិងហិរញ្ញវត្ថុ | 591.8 | 6.9 | 584.9 | |
| នា.ព័ត៌មាន និងកិច្ចការអាស៊ាន | 1,152.9 | 95.6 | 1,057.3 | |
| នា.នីតិកម្ម | 1,092.5 | 33.7 | 1,058.8 | |
| នា.សំណង់ | 6,918.8 | 31.1 | 6,887.7 | |
| នា.សម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | 3,645.0 | 319.5 | 3,325.5 | |
| នា.រដ្ឋបាល | 2,974.4 | 44.1 | 2,930.3 | |
| នា. ទ.វប្បធម៌ និងអាហារូបករណ៍ | 5,118.7 | 115.3 | 5,003.4 | |
| នា.ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | 1,748.8 | 64.4 | 1,684.4 | |
| នា.គោលនយោបាយ | 1,476.9 | 42.9 | 1,434.0 | |
| នា.ពិនិត្យតាមដាន និង វាយតម្លៃ | 1,030.6 | 32.8 | 997.8 | |
| នា.បច្ចេកវិទ្យាពត៌មាន | 1,106.8 | 51.6 | 1,055.2 | |
| មន្ទីររាជធានីខេត្ត | 2,833,147.6 | 840.0 | 2,832,307.6 | |

៥-ក្នុងករណីអង្គភាពមួយចំនួន បានពិនិត្យឃើញថា ទិន្នន័យឥណទានថវិកាកាត់សន្សំឬព្យួរខាងលើ មិនត្រឹមត្រូវ សូមផ្តល់ព័ត៌មានត្រឡប់ជូនក្រុមការងារនាយកដ្ឋានហិរញ្ញវត្ថុតាមរយៈប្រព័ន្ធអេឡិចត្រូនិច (Telegram) របស់កម្មវិធីនីមួយៗ ជាបន្ទាន់។

៦-គ្រប់អង្គភាព ត្រូវរៀបចំវិភាជន៍ឥណទានថវិកាឡើងវិញទៅតាមចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកា(កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព) ឱ្យចំទិសដៅនិងសកម្មភាពអាទិភាពជាចម្បង ដើម្បីចូលរួមចំណែកសម្រេចនូវគោលបំណងនិងគោលនយោបាយរបស់ក្រសួង។ ដោយឡែក អង្គភាពក៏ត្រូវកែសម្រួលតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន ផែនការលទ្ធកម្មប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ(AOP)ជាថ្មីធ្វើយ៉ាងណាឱ្យមានសង្គតិភាពទៅនឹងឥណទានថវិកាក្រោយកាត់តម្រឹម។

៧-គ្រប់អង្គភាព ត្រូវបញ្ជូនឥណទានថវិកា ដែលបានកែតម្រូវ(ត្រង់ចំណុចទី៦) មកនាយកដ្ឋានហិរញ្ញវត្ថុតាមប្រព័ន្ធអេឡិចត្រូនិច(Telegram)របស់កម្មវិធីនីមួយៗ យ៉ាងយូរត្រឹម**ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង១១:៣០នាទីព្រឹក** ជាកំហិត និងត្រូវបញ្ជូនឯកសារ Hard Copy ដោយមានចុះហត្ថលេខាតាមឋានានុក្រម ផងដែរ។

៨-នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកជាអ្នកសម្របសម្រួលជាមួយអង្គភាពក្រោមឱវាទក្រសួងនិង បូកសរុបឥណទានថវិកា ហើយបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទាន់ពេលវេលា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបនិងចាត់ចែង អនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់និងទាន់ពេលវេលា តាមការគួរ។

**សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូនៈ**

- គ្រប់អគ្គនាយកដ្ឋាន
- គ្រប់គ្រឹះស្ថានឧត្តមសិក្សា
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡា
- គ្រប់អង្គភាពក្រោមឱវាទទីស្តីការក្រសួង
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  " ដើម្បីមុខការ "

-កាលប្បវត្តិ

-ឯកសារ .នា. ហិរញ្ញវត្ថុ